គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee for Cambodia
Comité de Coopération Pour le Cambodge

**ទស្សនវិស័យ:** ការអភិវឌ្ឍប្រកបដោយនិរន្តរភាពសម្រាប់ប្រទេសកម្ពុជា
**Vision:** Sustainable Development for Cambodia

# សេចក្តីថ្លែងការណ៍ស្តីពីលទ្ធផល

## *កិច្ចប្រជុំកំពូលប្រចាំឆ្នាំ ២០១៧ របស់គណៈកម្មាធិការ គ.ស.ក*

## *ថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០១៨ រាជធានីភ្នំពេញ ប្រទេសកម្ពុជា*

កិច្ចប្រជុំកំពូលប្រចាំឆ្នាំ (AGM) គឺជាវាទិកាធំបំផុតរបស់គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) និងសមាជិករបស់ខ្លួន។ ព្រឹត្តិការណ៍នេះ រៀបចំឡើងដោយមានការចូលរួមពីតួអង្គអភិវឌ្ឍន៍ផ្សេងទៀត រួមទាំងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិល ដែលមិនត្រឹមតែដើម្បីផ្តល់ព័ត៌មានជូនពួកគេអំពីវឌ្ឍនភាពនៃសមាជិកភាពរបស់ គ.ស.ក ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីពិភាក្សាប្រកបដោយបរិយាប័ន្ន និងដើម្បីស្វែងរកដំណោះស្រាយចំពោះបញ្ហាអភិវឌ្ឍន៍រួមគ្នាផងដែរ។

នៅឆ្នាំនេះ សិក្ខាកាមចំនួន ២៧០ នាក់ដែលជាសមាជិករបស់គណៈកម្មាធិការ គ.ស.ក និងដៃគូនានាបានចូលរួមក្នុងកិច្ចប្រជុំកំពូលប្រចាំឆ្នាំនេះ ដែលត្រូវបានរៀបចំធ្វើឡើងស្ថិតក្រោមប្រធានបទ៖ "លំហសង្គមស៊ីវិលក្នុងមូលដ្ឋានីយកម្មនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព" និង ប្រធានបទពិភាក្សាចំនួន ៦ រួមមាន ១) ការផ្តល់ហិរញ្ញប្បទានដល់សង្គមស៊ីវិលសម្រាប់ការអភិវឌ្ឍ ២) សង្គមស៊ីវិល និងកិច្ចសហប្រតិបត្តិការល្អ ៣) អនុលោមភាពផ្នែកច្បាប់ (ពន្ធដារ ច្បាប់ស្តីពីសមាគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល (LANGO) ច្បាប់ស្តីពីការងារ របបសន្តិសុខសង្គម (NSSF) និងច្បាប់ដែលពាក់ព័ន្ធផ្សេងទៀត) ៤) តើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) អាចជំរុញ ឬរារាំងប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល? ៥) ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍថ្នាក់ក្រោមជាតិ និង ៦) សារៈសំខាន់នៃបណ្តាញថ្នាក់ខេត្តក្នុងការលើកកម្ពស់ភាពជាម្ចាស់ និងនិរន្តរភាព។

កិច្ចប្រជុំកំពូលប្រចាំឆ្នាំ បានសាទរដល់ការអនុម័តគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (SDGs) និងកិច្ចខិតខំប្រឹងប្រែងបន្តបន្ទាប់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងមូលដ្ឋានីយកម្មរបៀបវារៈនេះក្នុងរយៈពេល ១៥ ឆ្នាំមកនេះ តាមរយៈការធ្វើសមាហរណកម្មដំណើរការ និងខ្លឹមសារនានាដែលលើកកម្ពស់គោលការណ៍នៃ "ការមិនទុកនរណាម្នាក់ចោល" និងភាពជាដៃគូពហុភាគី។ ទាំងនេះអាចឲ្យភាគីពាក់ព័ន្ធទាំងអស់ចែករំលែកចំណេះដឹង ជំនាញ បច្ចេកវិទ្យា និងធនធានហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការសម្រេចបាននូវ SDGs និងផែនការថ្នាក់ជាតិនានា។ ក្រៅពី SDGs សង្គមស៊ីវិលវាយតម្លៃយ៉ាងខ្ពស់នូវបរិយាបន្នៃភាពជាដៃគូពហុភា



www.ccc-cambodia.org
info@ccc-cambodia.org
T +៨៥៥ (0)២៣ ២១៤ ១៥២
F +៨៥៥ (0)២៣ ២១៦ ០០៩

ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ខ័ណ្ឌចំការមន ប្រអប់សំបុត្រ 885 រាជធានីភ្នំពេញ
ប្រទេសកម្ពុជា

Accountability គណនេយ្យភាព
25/08/2015 GPP 24/08/2018
Symbol of Trust

គឺថាជាសមាសធាតុដ៏សំខាន់មួយនៃផែនការអនុវត្ត (IP3) នៃការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម (ISAF)។ ការណ៍នេះ ពិតជាអាចលើកកម្ពស់ការចូលរួមរបស់សង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងៗនៅក្នុងការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ។

ស្របពេលជាមួយគ្នានេះដែរ សិក្ខាកាមក្នុងកិច្ចប្រជុំកំពូលប្រចាំឆ្នាំ មានការព្រួយបារម្ភខ្លាំងអំពីបញ្ហាបរិយាកាសអំណោយផលសម្រាប់វិស័យរបស់ពួកគេ ជាពិសេសទាក់ទងនឹងលំហាពលរដ្ឋ ក្របខ័ណ្ឌច្បាប់ និរន្តរភាពហិរញ្ញវត្ថុ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការវិមជ្ឈការ និងប្រជាធិបតេយ្យនីយកម្ម និងភាពជាដៃគូប្រកបដោយបរិយាបន្នសម្រាប់ការអភិវឌ្ឍ។ លើសពីនេះទៀត កិច្ចប្រជុំប្រចាំឆ្នាំបានឯកភាពថា សង្គមស៊ីវិលនៅតែជួបប្រទះនូវបញ្ហាប្រឈមជាមួយនឹងភាពមិនស៊ីសង្វាក់គ្នា និងកង្វះការចូលរួមប្រកបដោយអត្ថន័យក្នុងចំណោមតួអង្គសំខាន់ៗនៅទូទាំងដំណើរការ SDGs រហូតមកដល់ពេលនេះ ដូច្នេះកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតត្រូវការជាចាំបាច់សម្រាប់វិស័យនេះ បន្ទាប់ពីដំណាក់កាលមូលដ្ឋានីយកម្ម SDGs។ បើទោះជាថា បញ្ហាប្រឈមទាំងនេះកើតមានក៏ដោយ ក៏កិច្ចប្រជុំកំពូលប្រចាំឆ្នាំបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តរបស់ពួកគេ និងការត្រៀមខ្លួនរួចជាស្រេចក្នុងការចូលរួមក្នុងការអនុវត្ត SDGs និង ISAF។

សិក្ខាកាមក្នុងកិច្ចប្រជុំកំពូលប្រចាំឆ្នាំ សម្តែងនូវក្តីបារម្ភយ៉ាងខ្លាំង ចាប់តាំងពីភាពអាចរស់បានផ្នែកហិរញ្ញវត្ថុរបស់វិស័យសង្គមស៊ីវិលកាន់តែធ្លាក់ចុះនាពេលថ្មីៗនេះមក។ ប្រភពនៃការផ្តល់មូលនិធិសម្រាប់អង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងលើជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) និងការផ្តល់មូលនិធិរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ខណៈពេលដែលសមត្ថភាពរបស់វិស័យនេះក្នុងការធ្វើពិពិធកម្មប្រាក់ចំណូលរបស់ខ្លួននៅតែមានកម្រិតនៅឡើយ។ បើទោះបីជាប្រទេសកម្ពុជាបានឆ្លងចូលទៅក្នុងឋានៈជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប (LMIC) រួចទៅហើយក្តី ក៏កិច្ចប្រជុំកំពូលប្រចាំឆ្នាំ ជឿជាក់យ៉ាងខ្លាំងថា សង្គមស៊ីវិលក្នុងប្រទេសកម្ពុជា នៅតែចាំបាច់ត្រូវការជំនួយផ្នែកអភិវឌ្ឍន៍ និងជំនួយផ្សេងៗជាបន្តទៀត ដែលលើកកម្ពស់និរន្តរភាពរបស់សង្គមស៊ីវិល។ ក្នុងពេលជាមួយគ្នានេះដែរ កិច្ចប្រជុំកំពូលប្រចាំឆ្នាំ កោតសរសើរដល់គំនិតផ្តួចផ្តើមនានាក្នុងពេលថ្មីៗនេះរបស់គណៈកម្មាធិការ គ.ស.ក ដូចជាការបង្កើតមូលនិធិសង្គមស៊ីវិល ការអភិវឌ្ឍសមត្ថភាពស្តីពីការកៀងគរធនធាន ភាពស្ម័គ្រចិត្តនិយមដែលអាចឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ។

កិច្ចប្រជុំកំពូលប្រចាំឆ្នាំ សង្កត់ធ្ងន់ទៅលើក្តីបារម្ភជាពិសេសរបស់ពួកគេអំពីការធ្លាក់ចុះជារួមនៃលំហររបស់សង្គមស៊ីវិល ការរារាំងពួកគេមិនឲ្យអនុវត្តសកម្មភាពរបស់ខ្លួន ជាពិសេសសម្រាប់អង្គការសង្គមស៊ីវិលដែលធ្វើការងារលើវិស័យរសើបនានា ដូចជា វិស័យសិទ្ធិមនុស្ស ការតស៊ូមតិ ការប្រឆាំងអំពើពុករលួយ ការ



www.ccc-cambodia.org
info@ccc-cambodia.org
T +៨៥៥ (0)២៣ ២១៤ ១៥២
F +៨៥៥ (0)២៣ ២១៦ ០០៩

ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ខ័ណ្ឌចំការមន ប្រអប់សំបុត្រ 885 រាជធានីភ្នំពេញ
ប្រទេសកម្ពុជា

គ្រប់គ្រងធនធានធម្មជាតិ និងការបោះឆ្នោតជាដើម។ លើសពីនេះទៀត សង្គមស៊ីវិលបន្តទទួលរងបទពិសោធលក្ខខណ្ឌតម្រូវ/ការអនុវត្តច្បាប់ឥតឈប់ឈរ ជាពិសេសទាក់ទងនឹងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីពន្ធដារ ច្បាប់ស្តីពីការងារ និងរបបសន្តិសុខសង្គម។ សេវាកម្មគាំទ្រផ្នែកច្បាប់ដែលណែនាំទៅសមាជិកភាពរបស់គណៈកម្មាធិការ គ.ស.ក អាចដោះស្រាយបានមួយផ្នែកនៃបញ្ហាទាំងនេះ ប៉ុន្តែនៅតែមានកម្រិតតិចតួច បើធៀបនឹងតម្រូវការ។ បើទោះជាមានតម្រូវការយ៉ាងច្បាស់មួយក្នុងការបង្កើនជំនួយផ្នែកច្បាប់ឲ្យដល់កម្រិតអតិបរមាសម្រាប់សង្គមស៊ីវិលក៏ដោយ ក៏ដំណើរការផ្នែកច្បាប់ ក៏ត្រូវធ្វើឡើងក្នុងរូបភាពជាការផ្តល់ប្រឹក្សាពេញលេញជាមួយសង្គមស៊ីវិល និងអ្នកទាំងឡាយណាដែលរងផលប៉ះពាល់ផងដែរ ដើម្បីធានាឲ្យបាននូវអន្តរកម្មប្រកបដោយប្រសិទ្ធភាពក្នុងកិច្ចពិភាក្សាអំពីគោលនយោបាយ។

កិច្ចប្រជុំកំពូលប្រចាំឆ្នាំ បានលើកឡើងនូវទិដ្ឋភាពសំខាន់មួយផ្សេងទៀតអំពីសហាត្ថិភាព និងកិច្ចសហប្រតិបត្តិការនៅក្នុងសង្គមស៊ីវិលខ្លួនឯងផ្ទាល់។ រហូតមកដល់ពេលនេះ ភាពស៊ីជម្រៅនៃកិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គការសង្គមស៊ីវិល ដែលធ្វើការងារក្នុងវិស័យផ្សេងៗគ្នា និងសូម្បីតែធ្វើការនៅទូទាំងបណ្តាយអង្គការសង្គមស៊ីវិល នៅមានកម្រិតទាបនៅឡើយ។ សិក្ខាកាមនៃកិច្ចប្រជុំនេះ មានអារម្មណ៍កោតសរសើរចំពោះលទ្ធផលរកឃើញនានាពីការស្រាវជ្រាវថ្មីនេះ ដែលគ្រប់គ្រងដោយគណៈកម្មាធិការ គ.ស.ក ដែលការរៀបចំអភិបាលកិច្ចក្នុងចំណោមបណ្តាញអង្គការសង្គមស៊ីវិល គួរត្រូវបានកែលម្អ ហើយនៅពេលនោះទម្រង់ជាក់លាក់មួយនៃកិច្ចសហប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល គួរត្រូវបានចាត់ទុកថាជាអាទិភាពរួមគ្នាមួយ។ ការពិភាក្សាដែលត្រូវបានធ្វើឡើងនៅឯកិច្ចប្រជុំកំពូលប្រចាំឆ្នាំ ក៏បានផ្តោតការយកចិត្តទុកដាក់លើតម្រូវការនៃការអភិវឌ្ឍសមត្ថភាពបន្ថែមផងដែរ ចំពោះបណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្ត ដែលធ្វើការងារយ៉ាងជិតស្និទ្ធិនៅសហគមន៍ ដើម្បីដោះស្រាយបញ្ហារបស់ពួកគេ។

ដើម្បីធ្វើមូលដ្ឋានីយកម្ម SDGs ប្រកបដោយប្រសិទ្ធភាពទៅក្នុងបរិបទកម្ពុជា និងដើម្បីលើកកម្ពស់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅកម្ពុជានោះ កិច្ចប្រជុំកំពូលប្រចាំឆ្នាំ បានលើកឡើងនូវចំណុចសំខាន់ៗដូចខាងក្រោមសម្រាប់ភាគីពាក់ព័ន្ធខាងក្រោម៖

រាជរដ្ឋាភិបាលកម្ពុជា៖



www.ccc-cambodia.org
info@ccc-cambodia.org
T +៨៥៥ (0)២៣ ២១៤ ១៥២
F +៨៥៥ (0)២៣ ២១៦ ០០៩

ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ខណ្ឌចំការមន ប្រអប់សំបុត្រ 885 រាជធានីភ្នំពេញ
ប្រទេសកម្ពុជា

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ
GPP
25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃទំនុកចិត្ត

- បន្តគាំទ្រអង្គការសង្គមស៊ីវិល ដើម្បីចូលរួមក្នុងរបៀបវារៈអភិវឌ្ឍន៍សំខាន់ៗ និងកំណែទម្រង់នានា ដូចជា កំណែទម្រង់ច្បាប់ ការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការអនុវត្តក្របខ័ណ្ឌគណនេយ្យភាពសង្គម (ISAF)។
- ធានាឲ្យបាននូវបរិស្ថានអំណោយផលសម្រាប់អង្គការសង្គមស៊ីវិល ជាពិសេសទាក់ទងនឹងក្របខ័ណ្ឌច្បាប់ ភាពជាដៃគូពោរពេញដោយអត្ថន័យក្នុងការអភិវឌ្ឍគោលនយោបាយ និងការផ្តល់ហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ។
- លើកកម្ពស់ភាពជាដៃគូពហុភាគី និងអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការប្តេជ្ញាចិត្តនៅក្នុងភាពជាដៃគូសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពក្នុងទីក្រុងប៊ូសាន និង SDGs (SDGs របស់កម្ពុជាទាំងអស់ ជាពិសេស SDGs 16 និង 17 និងគោលការណ៍នៃការមិនទុកនរណាម្នាក់ចោល)។ ប្រការសំខាន់នោះគឺត្រូវពង្រឹងឡើងវិញនូវគំរូភាពជាដៃគូពហុភាគីដែលមានស្រាប់សំខាន់ៗ ដូចដែលមានចែងក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រភាពជាដៃគូ (DCPS) ឆ្នាំ ២០១៤-២០១៨ ជាពិសេស រៀបចំកិច្ចប្រជុំប្រឹក្សាយោបល់ភាពរវាងរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលប្រចាំឆ្នាំថ្នាក់ខ្ពស់ និងបង្កើតកិច្ចប្រជុំថ្មីៗប្រសិនបើចាំបាច់ ដើម្បីបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះយន្តការភាពជាដៃគូទាំងនោះ។
- លើកកម្ពស់គម្រោងលើកទឹកចិត្ត ដូចជាការលើកលែងពន្ធសម្រាប់អង្គការសង្គមស៊ីវិល ការបែងចែកថវិកាជាតិប្រចាំឆ្នាំ និងគំនិតផ្តួចផ្តើមផ្សេងៗ។ រដ្ឋាភិបាលគួរគាំទ្រមូលនិធិសង្គមស៊ីវិលដែលជាយន្តការមួយក្នុងចំណោមយន្តការប្រកបដោយថាមពល ដើម្បីលើកកម្ពស់និរន្តរភាពហិរញ្ញវត្ថុសម្រាប់វិស័យសង្គមស៊ីវិល។
- សហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធទាំងអស់ រួមទាំងអង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីបង្កើតក្របខ័ណ្ឌច្បាប់ស្តីពីប្រតិបត្តិការដោយការទទួលខុសត្រូវរបស់ធុរកិច្ច។

ដៃគូអភិវឌ្ឍន៍/ម្ចាស់ជំនួយ៖

- គាំទ្រអង្គការសង្គមស៊ីវិលតាមរយៈការយោគយល់ និងការលើកកម្ពស់បរិយាកាស អំណោយផលតាមរយៈការមានគោលនយោបាយសង្គមស៊ីវិលជារួម ផែនទីបង្ហាញផ្លូវ និង/ឬសរសេរស្តម្ភរបស់សង្គមស៊ីវិល។
- លើកកម្ពស់ និងគាំទ្រដៃគូរបស់អង្គការសង្គមស៊ីវិលឆ្ពោះទៅរកសុខដុមនីយកម្ម និងអភិបាលកិច្ចល្អក្នុងវិស័យនេះ។ ការគាំទ្រដល់ប្រព័ន្ធបញ្ជាក់ពីអភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ (GPP) ត្រូវបានស្នើសុំឲ្យមានជាខ្លាំង។



www.ccc-cambodia.org
info@ccc-cambodia.org
T +៨៥៥ (0)២៣ ២១៤ ១៥២
F +៨៥៥ (0)២៣ ២១៦ ០០៩

ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ខ័ណ្ឌចំការមន ប្រអប់សំបុត្រ 885 រាជធានីភ្នំពេញ
ប្រទេសកម្ពុជា

Accountability គណនេយ្យភាព
អភិបាលកិច្ច និងការប្រតិបត្តិប្រកបដោយវិជ្ជាជីវៈ
GPP
25/08/2015 24/08/2018
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត

- លើកកម្ពស់គំនិតផ្តួចផ្តើមរបស់សង្គមស៊ីវិលដែលទើបដាក់ចេញថ្មីៗ ជាពិសេសគំនិតផ្តួចផ្តើមស្តីពីមូលនិធិសង្គមស៊ីវិល គោលការណ៍ណែនាំស្តីពីប្រតិបត្តិការល្អ និងនិរន្តរភាពរបស់អង្គការសហគមន៍ សន្និបាតរបស់អង្គការសង្គមស៊ីវិល និងកិច្ចខិតខំប្រឹងប្រែងផ្សេងៗទៀត។
- ធានាឲ្យមានការបន្តផ្តល់ជំនួយអភិវឌ្ឍន៍ និងនៅទីណាដែលអាចធ្វើបាន បង្កើនការគាំទ្រផ្នែកផ្តល់មូលនិធិ។ ការគាំទ្រនេះ គួរកើតមានជាមួយនឹងលក្ខខណ្ឌដែលមានការបន្ធូរបន្ថយសម្រាប់អង្គការសង្គមស៊ីវិលក្នុងស្រុក ដើម្បីចូលរួមក្នុងដំណើរការដេញថ្លៃ ការលើកកម្ពស់វិធីសាស្ត្រដែលផ្អែកលើសិទ្ធិមនុស្ស ភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងភាពជាម្ចាស់កម្មសិទ្ធិក្នុងស្រុក និងនិរន្តរភាព។

វិស័យឯកជន៖

- បង្ហាញឲ្យដឹងក្នុងវិស័យនេះនូវអាទិភាពអភិវឌ្ឍន៍ដែលនៅមាន ជាពិសេសកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាពទីក្រុងប៊ូសាន និងគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព (SDGs)។
- រួមគ្នាតស៊ូមតិជាមួយអង្គការសង្គមស៊ីវិល ដើម្បីឲ្យមានកិច្ចពិភាក្សារវាងវិស័យឯកជន-សាធារណៈ និងអង្គការសង្គមស៊ីវិល ដើម្បីលើកកម្ពស់ភាពចុំច្រើនសម្រាប់តួអង្គទាំងអស់ និងដើម្បីលើកកម្ពស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព។
- លើកកម្ពស់ភាពជាម្ចាស់ជើងឯក និងការអនុវត្តសិទ្ធិធុរកិច្ច និងសិទ្ធិមនុស្សនៅទូទាំងវិស័យធុរកិច្ច ព្រមទាំងការប្រតិបត្តិល្អបំផុតពីប្រទេសផ្សេងៗ។
- គាំទ្រមូលនិធិសង្គមស៊ីវិលដែលទើបបង្កើតថ្មី ទាំងតាមរយៈការគាំទ្រផ្នែកបច្ចេកទេស និងទាំងហិរញ្ញវត្ថុ ដើម្បីឲ្យសង្គមស៊ីវិលបន្តដើរតួនាទីសំខាន់ចំពោះការអភិវឌ្ឍប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព និងតាមបែបប្រជាធិបតេយ្យ។

សង្គមស៊ីវិល៖

- លើកកម្ពស់ការសម្របសម្រួលក្នុងចំណោម និងនៅទូទាំងវិស័យនានា។ កិច្ចប្រជុំកំពូលនេះ ស្នើឲ្យគណៈកម្មាធិការ គ.ស.ក ក្នុងនាមជាអង្គការសមាជិកភាព ធ្វើការងារជាមួយបណ្តាញអង្គការសង្គមស៊ីវិលផ្សេងទៀត ដើម្បីឲ្យមានកិច្ចពិភាក្សាជាប្រចាំនៅក្នុងវិស័យនេះ (ឧ. សន្និបាទរបស់អង្គការសង្គមស៊ីវិលប្រចាំឆ្នាំ) ដើម្បីដោះស្រាយបញ្ហារួមរបស់ពួកគេ និងដើម្បីអភិវឌ្ឍយុទ្ធសាស្ត្ររួម។
- ពង្រឹងការយល់ដឹង សមត្ថភាព និងវិជ្ជាជីវៈរបស់ពួកគេសម្រាប់ការឆ្លើយតបប្រកបដោយនវានុវត្តន៍ទៅនឹងបញ្ហាប្រឈមផ្នែកអភិវឌ្ឍន៍ ជាពិសេសក្នុងដំណើរការមូលដ្ឋានីយកម្ម និងរបៀបវារៈបន្តបន្ទាប់របស់ SDGs។


www.ccc-cambodia.org
info@ccc-cambodia.org
T +៨៥៥ (0)២៣ ២១៤ ១៥២
F +៨៥៥ (0)២៣ ២១៦ ០០៩
ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ខណ្ឌចំការមន ប្រអប់សំបុត្រ 885 រាជធានីភ្នំពេញ
ប្រទេសកម្ពុជា
Accountability គណនេយ្យភាព
25/08/2015 GPP 24/08/2018
Symbol of Trust និមិត្តសញ្ញានៃទំនុកចិត្ត

- លើកកម្ពស់សមត្ថភាពអនុលោមភាពផ្នែកច្បាប់ ភាពជាម្ចាស់កម្មសិទ្ធិ និងគាំទ្រដល់អង្គការសង្គមស៊ីវិលក្នុងស្រុក ខណៈដែលកំណត់ឲ្យបានច្បាស់លាស់នូវរបៀបវារៈ និងកិច្ចសហប្រតិបត្តិការរវាងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។
- គាំទ្រគំនិតផ្តួចផ្តើមរបស់អង្គការសង្គមស៊ីវិលដែលមានស្រាប់ ដូចជា ប្រព័ន្ធបញ្ជាក់ការធ្វើការងារស្ម័គ្រចិត្ត មជ្ឈមណ្ឌលសង្គមស៊ីវិល ការអភិឌ្ឍសមត្ថភាពស្ថាប័នសន្តនិយមសង្គមស៊ីវិល មូលនិធិសង្គមស៊ីវិល សន្និបាតអង្គការសង្គមស៊ីវិល ជំនួបអតីតបុគ្គលិកអង្គការសង្គមស៊ីវិល និងកិច្ចខិតខំប្រឹងប្រែងផ្សេងៗ។



www.ccc-cambodia.org
info@ccc-cambodia.org
T +៨៥៥ (០)២៣ ២១៩ ១៥២
F +៨៥៥ (០)២៣ ២១៦ ០០៩

ផ្ទះលេខ ៩-១១ ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១
ខ័ណ្ឌចំការមន ប្រអប់សំបុត្រ 885 រាជធានីភ្នំពេញ
ប្រទេសកម្ពុជា

Accountability គណនេយ្យភាព
25/08/2015 GPP 24/08/2018
Symbol of Trust និមិត្តសញ្ញានៃភាពទុកចិត្ត